# ជម្ងឺមហារីក ១០១
# មេរៀនទី ៣




រោគវិនិច្ឆ័យនិងដំណាក់ការនៃជម្ងឺមហារីក

# យើងនឹងរៀនដើម្បីពន្យល់ដល់ក្រុមគ្រួសារ និងមិត្តភក្តិយើងអំពី :

- តើពាក្យថា បាយយ៉ូបស៊ី (biopsy) មានន័យដូចម្តេច?
- តើដុំពកទាំងឡាយមានលក្ខណៈខុសគ្នាបែបណាខ្លះ?
- ឧទាហរណ៍អំពីដំណាក់ការនៃជម្ងឺមហារីកនិងអត្ថន័យរបស់វា។
- ហេតុអ្វីការចាត់ជាដំណាក់ការមានសារៈសំខាន់?
- តើខ្មែរយើងយល់យ៉ាងណាដែរចំពោះដំណាក់ការវិវត្តន៍របស់ជម្ងឺមហារីកនេះ?

# តើរោគវិនិច្ឆ័យគឺជាអ្វី?

វាគឺជាការវិនិច្ឆ័យរោគ ដើម្បីបញ្ជាក់ពីការដែលជម្ងឺមហារីកអាចកើតមាន

(អាការៈរោគ ឬការពិនិត្យរោគ)

↓

គ្រូពេទ្យនឹងធ្វើបាយយូបស៊ី

(ធ្វើការវះកាត់ច្រិបយកជាលិកាមួយដុំតូច)

↓

ការពិនិត្យមើលរោគដោយប្រើកែវឆ្លុះ

(អាចប្រាប់បញ្ជាក់ឲ្យគ្រូពេទ្យដឹងថា៖ មានដុំពកមែន ឬមិនមែន)

↙ ↘

ដុំពកមិនមែនជាមហារីក ដុំពកដែលជាមហារីក

# បាយយូបស៊ី

- អិនដូស្កូពី (Endoscopy)
- បាយយូបស៊ីដោយប្រើម្ជុល (Needle Biopsy)
- បាយយូបស៊ីដោយប្រើការវះកាត់ (Surgical Biopsy)
    - បាយយូបស៊ី ខាងក្រៅ (Excisional biopsy)
    - បាយយូបស៊ី ខាងក្នុង (Incisional biospsy)

# លទ្ធផលនៃការធ្វើបាយយូបស៊ីប្រាប់យើងអំពី ៖

- បើដុំពកនោះជាមហារីក ឬមិនមែនជាមហារីក
- តើវាជាជម្ងឺមហារីកប្រភេទអ្វី?
- តើដុំពកនោះមានលក្ខណៈបែបណា?

តើវាលូតលាស់លឿនខ្លាំងឬទេ?

# ដំណាក់ការនៃជម្ងឺមហារីក

- អ៊ិន ស៊ីទូ (នៅខាងក្នុង) - In situ
- Local
- Regional
- Distant

# ដំណាក់ការនៃជម្ងឺមហារីក

- ដំណាក់ការ ទី១
- ដំណាក់ការ ទី២
- ដំណាក់ការ ទី៣
- ដំណាក់ការ ទី៤

# តើហេតុអ្វីបានជាការចាត់ជាដំណាក់ការមានសារៈសំខាន់?

- ដំណាក់ការប្រាប់អោយយើងដឹងអំពីការវិវត្តន៍របស់ជម្ងឺ
- ការព្យាបាលអាស្រ័យទៅលើដំណាក់ការ និងប្រភេទពិតប្រាកដរបស់ជម្ងឺមហារីក។
- ដំណាក់ការជួយសំរេចជាមុនអំពីលក្ខណៈរោគ និងលទ្ធផលនៃការព្យាបាលរោគ (ការប៉ាន់ស្មានអំពីស្ថានភាពរបស់ជម្ងឺ និងលទ្ធផលចុងក្រោយរបស់ជម្ងឺ ជាពិសេសឱកាសដែល បានជាសះស្បើយវិញ)។

# តើបុរសខ្មែរយល់យ៉ាងណាដែរ  ចំពោះការវិនិច្ឆ័យដំណាក់ការជម្ងឺមហារីកក្រពេញប្រូស្តាត?

# អាត្រាកំណត់ហេតុនៃការវិនិច្ឆ័យជម្ងឺមហារីកប្រស្តេតក្នុងចំណោមបុរសជនជាតិអាស៊ី និងកោះប៉ាស៊ីហ្វិក នៅពេលដែលជម្ងឺទើបតែចាប់ផ្តើម មានលំដាប់ខ្ពស់ និងនៅពេលជម្ងឺមានសភាពធ្ងន់ធ្ងរមានលំដាប់ទាប ។

ការវិនិច្ឆ័យរោគឃើញនៅពេលជម្ងឺទើបតែចាប់ផ្តើម មានឱកាសព្យាបាលបានជាសះស្បើយច្រើន ។




ការវិនិច្ឆ័យរោគឃើញនៅពេលជម្ងឺមានសភាពធ្ងន់ធ្ងរអាចកាត់បន្ថយឱកាសព្យាបាលឲ្យជាសះស្បើយ ។



# តើស្ត្រីខ្មែរយល់យ៉ាងណាដែរ<br>អំពីការវិនិច្ឆ័យដំណាក់ការនៃ<br>ជម្ងឺមហារីកដោះ និងកស្បូន?

# អាត្រាកំណត់ហេតុនៃការវិនិច្ឆ័យជម្ងឺមហារីកដោះក្នុងចំណោមស្ត្រីជនជាតិអាស៊ី និងកោះប៉ាស៊ីហ្វិក នៅពេលជម្ងឺទើបតែចាប់ផ្តើមមានលំដាប់ខ្ពស់ជាងគេ និង នៅពេលជម្ងឺមានសភាពធ្ងន់ធ្ងរមានកំរិតទាប ។

ការវិនិច្ឆ័យជម្ងឺមហារីកដោះឃើញនៅពេលវាទើបតែចាប់ផ្តើម មានឱកាសព្យាបាលឲ្យបានជាសះស្បើយច្រើន ។




ការវិនិច្ឆ័យជម្ងឺមហារីកដោះឃើញនៅពេលវាមានសភាពធ្ងន់ធ្ងរ អាចកាត់បន្ថយឱកាសព្យាបាលឲ្យបានជាសះស្បើយ ។



# អាត្រាកំណត់ហេតុនៃការវិនិច្ឆ័យជម្ងឺមហារីកស្បូនក្នុងចំណោមស្ត្រីជនជាតិអាស៊ី និងកោះប៉ាស៊ីហ្វិក នៅពេលជម្ងឺទើបតែចាប់ផ្ដើម មានកំរិតទាប ថ្នាក់ទី២ និងនៅពេលដែលជម្ងឺមានសភាពធ្ងន់ធ្ងរមានកំរិតខ្ពស់ ថ្នាក់ទី៣ ។

**ការវិនិច្ឆ័យជម្ងឺឃើញនៅពេលវាទើបតែចាប់ផ្ដើម មានឱកាសព្យាបាលបានជាសះស្បើយច្រើន ។**




**ការវិនិច្ឆ័យជម្ងឺឃើញនៅពេលវាមានសភាពធ្ងន់ធ្ងរអាចកាត់បន្ថយឱកាសព្យាបាលឲ្យជាសះស្បើយ ។**



# តើខ្មែរយើងយល់យ៉ាងណាដែរ អំពីការវិនិច្ឆ័យដំណាក់ការនៃ ជម្ងឺមហារីកពោះវៀនធំ និងចុងពោះវៀនធំ?

# អាត្រាកំណត់ហេតុនៃការវិនិច្ឆ័យជម្ងឺមហារីកពោះវៀននិងចុងពោះវៀនធំ ក្នុងចំណោមស្ត្រីជនជាតិអាស៊ី និងកោះប៉ាស៊ីហ្វិក នៅពេលជម្ងឺទើបតែចាប់ផ្តើមមានកំរិតទាប ថ្នាក់ទី២ និងនៅពេលដែលជម្ងឺមានសភាពធ្ងន់ធ្ងរមានកំរិតខ្ពស់ ថ្នាក់ទី៣ ។

ការវិនិច្ឆ័យជម្ងឺមហារីកពោះវៀន និងចុងពោះវៀនធំឃើញនៅពេលវាទើបតែចាប់ផ្តើម នាំឲ្យមានឱកាសព្យាបាល បានជាសះស្បើយច្រើន ។




ការវិនិច្ឆ័យជម្ងឺមហារីកពោះវៀនធំ និងចុងពោះវៀនធំឃើញនៅពេលវាមានសភាពធ្ងន់ធ្ងរ អាចកាត់បន្ថយឱកាសព្យាបាលឲ្យបានជាសះស្បើយ ។



# អត្រាកំណត់ហេតុនៃការវិនិច្ឆ័យជម្ងឺមហារីកពោះវៀនធំ និងចុងពោះវៀនធំ ក្នុងចំណោមបុរសជនជាតិអាស៊ី និងកោះប៉ាស៊ីហ្វិក នៅពេលដែលជម្ងឺទើបតែចាប់ផ្តើម មានលំដាប់ខ្ពស់ និងនៅពេលជម្ងឺមានសភាពធ្ងន់ធ្ងរមានលំដាប់ទាប ។

ការវិនិច្ឆ័យរោគឃើញនៅពេលជម្ងឺទើបតែចាប់ផ្តើម មានឱកាសព្យាបាលបានជាសះស្បើយច្រើន ។




ការវិនិច្ឆ័យរោគឃើញនៅពេលជម្ងឺមានសភាពធ្ងន់ធ្ងរអាចកាត់បន្ថយឱកាសព្យាបាលឲ្យជាសះស្បើយ ។



# តើយើងបានពន្យល់ ...




- តើពាក្យថា បាយឃូបស៊ី មានន័យដូចម្តេច?
- តើដុំពកមានលក្ខណៈខុសគ្នាយ៉ាងណាខ្លះ?
- ដំណាក់ការនៃជម្ងឺមហារីក និងអត្ថន័យរបស់វាយ៉ាងណា?
- ហេតុអ្វីដំណាក់ការរោគមានសារៈសំខាន់?

# References:


American Gastroenterological Association (http://www.gastro.org/public/drdan-colc.html)

American Cancer Society www.cancer.org

National Cancer Institute's Cancer Information Service (http://cancernet.nci.nih.gov)

Harvard Center for Cancer Prevention (www.yourcancerrisk.harvard.edu)

# សូមអរគុណ!

សូមអរគុណ ដែលលោកអ្នកបានប្រើកម្មវិធីបង្រៀនអំពីជម្ងឺមហារីករបស់ Refugee and Immigrant Health Promotion Project នៃមន្ទីរពេទ្យ Harborview កម្មវិធីនេះ ឧបត្ថម្ភដោយ AANCART យើងខ្ញុំសូមអភ័យទោសពីសំណាក់លោកនិងលោកស្រី ចំពោះការខ្វះខាត ឬខុសឆ្គងទាំងអស់ ដែលមាននៅក្នុងកម្មវិធីនេះ។ សូមអរគុណ

# References:

American Gastroenterological Association (http://www.gastro.org/public/drdan-colc.html)

American Cancer Society www.cancer.org

National Cancer Institute's Cancer Information Service (http://cancernet.nci.nih.gov)

Harvard Center for Cancer Prevention (www.yourcancerrisk.harvard.edu)